# ការអធិស្ឋានសំរាប់ពិភពលោក

*"គេរួមចិត្តគំនិតគ្នា ហើយបន្លឺសំឡេង......" កិច្ចការ ៤:២៤*

**ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ**

ដោយរួមគ្នាជាមួយអ្នកជឿនៅពាសពេញពិភពលោកយើងប្រជួបជុំនៅថ្ងៃនេះ ដើម្បីថ្វាយព្រះកិត្តិនាម និងសិរីរុងរឿងដល់ព្រះនាមរបស់ព្រះអង្គ ។ យើងក្រាបនៅមុខបល្ល័ង្ករបស់ព្រះអង្គ ហើយទទួលស្គាល់ថា ព្រះអង្គគឺជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី ។គ្មាននរណារដូចព្រះអង្គឡើយ បរិសុទ្ធសុចរិតគ្រប់ការ ទាំងអស់ ។ យើងសូមចុះចូលចំពោះអំណាចរបស់ព្រះអង្គជាស្តេចនៃសកលលោកទាំងមូល ។ យើង អធិស្ឋាន អភិសេកព្រះអង្គនៅក្នុងដូងចិត្តរបស់យើង ដោយមានសំលេងតែមួយនិងលើកតម្កើងព្រះអង្គ នៅមុខ លោកិយ៍នេះ ។

*ព្រះអម្ចាស់អើយ មានតែព្រះអង្គទេដែលសក្តិសម នឹងការគោរព និងទទួលការសរសើរតម្កើង ពីយើង ។ យើងខ្ញុំសូមថ្វាយបង្គំព្រះអង្គតែមួយ ។*

**ព្រះបិតាដែលគង់នៅស្ថានបរមសុខ**

សូមអរព្រះគុណព្រះអង្គសំរាប់សេចក្តីស្រឡាញ់ចំពោះលោកិយ៍យ៉ាងខ្លាំងក្លា រហូតដល់ព្រះអង្គលះបង់ ព្រះរាជបុត្រារបស់ព្រះអង្គគឺ ព្រះយេស៊ូ គ្រិស្ត ឱ្យមកសុគតលើឈើឆ្កាងសំរាប់អំពើបាបយើង ។ យើងខ្ញុំសូមដឹង គុណព្រះអង្គ ដែលព្រះអង្គហៅយើងថាជាកូនស្ងួនភ្ងាររបស់ព្រះអង្គ ហើយយើងហៅព្រះអង្គ វិញជា ព្រះបិតា

ដោយសារតែជំនឿរបស់យើងក្នុងព្រះយេស៊ូគ្រិស្ត ជាព្រះសង្គ្រោះរបស់យើង ។ គ្មានអ្វីអាច បំបែកយើងចេញពីសេចក្តីស្រឡាញ់របស់ព្រះអង្គបានឡើយ ។

*យើងសូមអរព្រះគុណព្រះអង្គដែលបានចិញ្ចឹមយើងនៅក្នុងគ្រួសាររបស់ព្រះអង្គ ។ ឥឡូវនេះ យើងស្រែកហៅព្រះអង្គថា អាប្បា ព្រះបិតា!*

## ព្រះអង្គម្ចាស់ព្រះយេស៊ូគ្រិស្ត

ព្រះអង្គតែមួយប៉ុណ្ណោះដែលសក្តិសមនឹងបើកក្រាំងនៃប្រវត្តិសាស្ត្រ ដ្បិតព្រះអង្គត្រូវបានគេធ្វើគត់ ហើយ រំដោះយើងទៅឯព្រះវរបិតា តាមរយៈព្រះលោហិតរបស់ព្រះអង្គ ។យើងសូមសារភាពថា ព្រះអង្គគឺជា សិរសា នៃក្រុមជំនុំ និងជាព្រះអម្ចាស់ដែលគ្រងរាជលើស្ថានសួគ៌ និងផែនដី ។ សូមឱ្យមនុស្សពីគ្រប់ កុលសម្ព័ន្ធ ជនជាតិ និងភាសាក្លាយជាអ្នកដើរតាមព្រះអង្គយ៉ាងពិតប្រាកដ ។ សូមឱ្យព្រះរាជ្យ ព្រះអង តាំង នៅគ្រប់ប្រជាជាតិនានាលើផែនដីនេះ ដើម្បីអោយរដ្ឋាភិបាលគ្រប់គ្រងដោយ សុច្ចរិត និងយុត្តិធម៌ ។

សួមឱ្យដំណឹងល្អរបស់ទ្រង់បានឮដល់គ្រប់មនុស្សទាំងអស់ ។ សូមឱ្យព្រះពររបស់ទ្រង់នាំមកនូវ ការផ្លាស់ ប្រែ នៅក្នុងចំណោមនុស្សទាំងអស់ ។

ហើយសូមឱ្យព្រះនាមរបស់ព្រះអង្គបានថ្កើងឡើងចាប់តាំងពីថ្ងៃរះ រហូតដល់ថ្ងៃលិច ។

*ព្រះយេស៊ូគ្រិស្តអើយ ព្រះអង្គគឺជាអ្នកសង្គ្រោះលោកិយ៍នេះ និងជាអម្ចាស់លើអ្វីៗទាំងអស់ ។*

## ព្រះគុណ   និងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះបិតា

យើងសូមសារភាពថា យើងគឺជាមនុស្សមានបាប

ហើយផែនដីរបស់យើងមានពេញទៅដោយអំណាចនៃ អំពើបាប ។

ដួងចិត្តយើងត្រូវបានរងទុក្ខព្រួយដោយអំពើអយុត្តិធមិ ការស្អប់ កំហឹង និងអំពើហឹង្សា ។ យើងរងការអាម៉ាសដោយការគៀបសង្កត់ ការប្រកាន់ពូជសាសន៍ និងការបង្ហូរឈាមនៅក្នុងទឹកដីយើង ។

យើងសូមកាន់ទុក្ខសំរាប់ការបាត់បង់ជីវិតមនុស្សស្លូតត្រង់ដែលស្លាប់ដោយការយកកូនចេញពីផ្ទៃ សង្គ្រាម និង ភេរវកម្ម ការបៀតបៀននិងការធ្វើឃាតឥតហេតុផល ។

ផ្ទះយើងត្រូវបានខ្ទេចខ្ទាំដោយ ភាពអាត្មានិយម និងអំពើប្រាចាកសិលធមិ ។

ក្រុមជំនុំយើងត្រូវបានបាក់បែកដោយអំនួតនៃការបះបោរ ។

ទាំងអស់នេះគឺជាអំពើបាបដែលយើងអាចរកឃើញនៅលើផែនដីរបស់យើង

ព្រះអង្គបានរកឃើញ នៅ ក្នុងចំណោមរាស្ត្ររបស់ព្រះអង្គ ។

យើងបានធ្វើឱ្យព្រះអង្គព្រួយព្រះទ័យ និងនាំការអាម៉ាសដល់ព្រះនាម របស់ព្រះអង្គ ។

យើងសូមចូលមកបល្ល័ង្កនៃព្រះគុណរបស់ព្រះអង្គ នៅក្នុងវិនាទីនៃសេចក្តីត្រូវការនេះ ។

យើងទូលសុំការប្រណីសន្តោស និងជំនួយពីព្រះអង្គ ដើម្បីឱ្យចិត្តយើងទាំងអស់គ្នាបានកែប្រែ ។

*ព្រះបិតាដែលពេញដោយព្រះគុណ សូមបង្ហូរព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គលើយើង ។ សូមលើកលែងទោសយើងឱ្យរួចផុតពីបាប ។ សូមប្រោសទឹកដីយើងឱ្យបានជាផង ។*

## ព្រះវិញ្ញាណរបស់ព្រះដែលមានព្រះជន្មគង់នៅ

យើងសូមសារភាពថា យើងមិនអាចធ្វើអ្វីបានឡើយបើគ្មានព្រះអង្គនោះ ។

សូមចាក់បង្ហូរព្រះវិញ្ញាណ មក បំពេញមនុស្សទាំងអស់ ។

សូមផ្លាស់ប្រែក្រុមជំនុំឱ្យបានដូចព្រះយេស៊ូគ្រិស្ត ។ សូមបង្ហូរអំណាចរបស់ទ្រង់

ដើម្បីប្រោសអ្នកជម្ងឺឱ្យបានជា   អ្នកជាប់ជាឈ្លើយមានសេរីភាព

កំសាន្តចិត្តអស់អ្នកដែលមានទុក្ខ    និង បណ្តេញ ខ្មោចចេញពីមនុស្ស ។

សូមយាងមករំលាយបំណងចិត្តមនុស្សឱ្យមានសេចក្តីស្រឡាញ់ឡើងវិញ ។

សូមឆ្លើយតប់ចំពោះសម្រែកជនអនាថា ជនស្រែកឃ្លាន ជនគ្មានទីពឹង និងអ្នកដែលកំពុងស្លាប់ ។

សូម អោបកុមារកំព្រា ស្រ្តីមេម៉ាយ និងមនុស្សជរានៅក្នុងព្រះហស្ថរបស់ព្រះអង្គ ។

សូមបង្ហាញការ ប្រណីសន្តោសរបស់ព្រះអង្គ និងផ្តត់ផ្គង់សេចក្តីត្រូវការរបស់យើង ។

សូមប្រទានឱ្យយើងមានប្រាជ្ញា

និងការយល់ដឹងជ្រៅជ្រះដើម្បីដោះស្រាយបញ្ហាស្មុគស្មាញក្នុងពេលបច្ចុប្បន្ន ។

សូមជួយយើងប្រើប្រាស់ ធនធាននៅផែនដីនេះសំរាប់សុខុមាភាពរបស់មនុស្សទាំងអស់ ។

សូមចាក់បង្ហូរសេចក្តីស្រឡាញ់របស់ ព្រះអង្គក្នុងចិត្តយើង

និងបំពេញយើងដោយចិត្តអាណិតអាសូរ ។

*ព្រះវិញ្ញាណបរិសុទ្ធ យើងត្រូវការការណែនាំ និងការកំសាន្តចិត្តពីព្រះអង្គ ។    សូមយាងមកបំផ្លាស់បំប្រែចិត្តគំនិតរបស់យើង ។*

## ព្រះអង្គម្ចាស់ព្រះយេស៊ូគ្រិស្ត

ព្រះអង្គបានសុគត ប៉ុន្តែឥឡូវនេះមានព្រះជន្មរស់ឡើងវិញ

ដោយសារព្រះបិតាបានប្រទានឱ្យព្រះអង្គ មាននាមលើនាមទាំងអស់

ព្រះអង្គបានបំបាក់អំណាចនៃពួកមារឱ្យបរាជ័យទាំងស្រុង ។ យើងអធិស្ឋាន បំបែកបន្ទាយរឹងមាំ និងចិត្តវិជ្ជាដែលរារាំង និងការប្រឆាំងនឹងដំណឹងល្អរបស់ព្រះអង្គ ។ សូមដករបាំងដែលបាំងមនុស្សលោក ។ សូមរំដោះអ្នកដែលត្រូវបានសង្កត់សង្កិនដោយពួកវិញ្ញាណអាក្រក់ឱ្យមានសេរី ភាព ។ សូមបំបែកគុកនៃទាសករ អំណាចផ្តាច់ការ និងជម្ងឺ ។

សូមបំពេញយើងឱ្យមានចិត្តក្លាហាន ក្នុងការ ប្រកាសព្រះបន្ទូលរបស់ទ្រង់ដោយឥតភ័យខ្លាច និងប្រទានឱ្យយើងនូវវិញ្ញាណនៃការទូលអង្វរ ដើម្បី ស្មោះ ត្រង់អធិស្ឋានសំរាប់អ្នកបាត់បង់ ។
*ព្រះដ៏មានបទ្ធានុភាព សូមរំដោះយើងចេញពីពួកវិញ្ញាណអក្រក់ និងមារសាតាំង ។*

**ស្ដេចដ៏រុងរឿង**

សូមយាងមកប្រជាជាតិនានាលើផែនដីនេះ ។ យើងសូមស្វាគមន៍ព្រះអង្គ ដើម្បីសម្រេចរាជកិច្ចរបស់ ព្រះអង្គ នៅក្នុងទីក្រុងយើង ប្រជាជនយើង និងប្រទេសយើង ។ ឥឡូវ យើងលើកសំលេង យើងរួមគ្នា ជាមួយអ្នកជឿពីទ្វីបអាហ្វ្រិក និងអាស៊ី ពីបស្ចិមប្រទេស និងអឺរ៉ុប ពីទ្វីបអាមេរិកខាងជើងនិងខាងត្បូង និងពីកោះប៉ាស៊ីហ្វិក និងអូស្ត្រាលី — យើងរួមគ្នាស្រែកថា:
*សូមងើបព្រះសិរសាររបស់ព្រះអង្គឡើង ឱ ព្រះអង្គ ដែលជាច្រកចូលអើយ! សូមលើកទ្វារបូរាណ ដើម្បីឱ្យស្ដេចដ៏រុងរឿងយាងចុះមក!*

ពេលព្រះរាជកិច្ចព្រះអង្គរីកពាសពេញផែនដី ហើយព្រះពររបស់ព្រះអង្គមានពាសពេញផែនដី ពួកគេ នឹងស្វែងរកព្រះអង្គ ដោយសួរថា "តើនរណាជាស្ដេចដ៏រុងរឿង?"
យើងរួមគ្នាឆ្លើយថា:
*ទ្រង់គឺជាព្រះម្ចាស់ដ៏មានឫទ្ធានុភាព! មានព្រះពរហើយអស់អ្នកដែលមកដោយនៅ ក្នុងព្រះនាម របស់ព្រះអម្ចាស់!*

សូមបំពេញផែនដីឱ្យពេញដោយសិរីរុងរបស់ព្រះអង្គ ដូចទឹកនៅលើផ្ទៃសមុទ្រ ។
ព្រះវិញ្ញាណ និងកូនក្រមុំស្រែកថា:

*សូមព្រះយេស៊ូ យាងមក! អាម៉ែន!*